# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម** **ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** **ក្រសួងរ៉ែ និង ថាមពល**

**លេខ:** ១៧២ ពណ.សហវ.ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣១អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៥៧៦អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរ៉ែ និងថាមពល
- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ លើលិខិតលេខ ៥០១១សហវ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់រូបមន្ត សម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ដើម្បីឱ្យថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយប្រេងឥន្ធនៈឡើងចុះតាមតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិ ។ ការកំណត់រូបមន្តនេះ សម្រាប់ដាក់ឱ្យអនុវត្តតែទៅលើការលក់រាយប្រេងឥន្ធនៈប៉ុណ្ណោះ។

**ប្រការ ២.-**

រូបមន្តថ្លៃលក់រាយប្រេងឥន្ធនៈ នៅតាមបណ្តាស្ថានីយប្រេងឥន្ធនៈនៅកម្ពុជាត្រូវបានកំណត់ដូចខាងក្រោម ÷

តម្លៃរាយ/លីត្រ = មធ្យមភាគ MOPS + ពន្ធ + PREMIUM + អាករលើតម្លៃបន្ថែម (VAT OUT)

- **MOPS** (Mean of Platts Singapore) សំដៅលើតម្លៃមធ្យមភាគនៃផលិតផលប្រេងឥន្ធនៈលក់ដុំនៅប្រទេសសិង្ហបុរី ដែលចេញផ្សាយដោយក្រុមហ៊ុន Platts
- **PREMIUM** : សំដៅលើ ចំណាយទូទៅ + ពន្ធលើប្រាក់ចំណេញ + ប្រាក់ចំណេញ
- **ពន្ធ** : សំដៅលើ ពន្ធគយ + អាករបន្ថែម + អាករពិសេស
- ឧទាហរណ៍ៈ ថ្លៃលក់រាយប្រេងសាំងសម្រាប់ប្រើប្រាស់ចាប់ពីថ្ងៃទី១២ ដល់ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ តាមរូបមន្តខាងលើត្រូវគណនាដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. មធ្យមភាគ MOPS ចាប់ពីថ្ងៃទី០៧-១១ ខែមិថុនា ឆ្នាំ២០១៨ | | ០,៥២៥៨ ដុល្លារ |
| ២. ពន្ធ÷ | | ០,១៧៩១ ដុល្លារ |
| ពន្ធគយ | ០,០៧២៦ ដុល្លារ | |
| អាករបន្ថែម | ០,០២០០ ដុល្លារ | |
| អាករពិសេស | ០,០៨៦៥ ដុល្លារ | |
| ៣. PREMIUM | | ០,២០០០ ដុល្លារ |
| ៤. អាករលើតម្លៃបន្ថែម ១០% នៃ (១ + ២ + ៣) | | ០,០៩០៥ ដុល្លារ |
| ថ្លៃលក់រាយ/លីត្រ (១ + ២ + ៣ + ៤) | | ០,៩៩៥៤ ដុល្លារ |
| ជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ ៤០៦០ រៀល/ដុល្លារ | | **៤ ០៥០ រៀល** |

**ប្រការ ៣.-**

តម្លៃ Premium ត្រូវបានកំណត់០,២០ដុល្លារក្នុងមួយលីត្រ សម្រាប់ប្រេងសាំង។ ចំណែកតម្លៃ Premium សម្រាប់ប្រេងម៉ាស៊ូតត្រូវបានកំណត់០,២៣ដុល្លារក្នុងមួយលីត្រ (តម្លៃគិតជាដុល្លារអាមេរិករួចគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ចេញដោយធនាគារជាតិនៃកម្ពុជា) ។ ស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជាអាចលក់ប្រកួតប្រជែងក្នុងតម្លៃមួយទាបជាងថ្លៃ ដែលបានគណនា ដោយរូបមន្តខាងលើ។

**ប្រការ ៤.-**

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្ម ត្រូវគណនាថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាតាមរូបមន្ត ខាងលើ និងចេញថ្លៃលក់រាយជូនក្រុមហ៊ុនប្រេងឥន្ធនៈនៅរៀងរាល់ថ្ងៃទី០១ និងថ្ងៃទី១៦ នៃខែនីមួយៗ។

**ប្រការ ៥.-**

គ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ត្រូវមានប្រភេទផលិតផលប្រេងសាំងធម្មតា និងប្រភេទផលិតផលប្រេង ម៉ាស៊ូតលក់ក្នុងតម្លៃមិនលើសពីថ្លៃដែលបានកំណត់ដូចប្រការ៤ នៃប្រកាសអន្តរក្រសួងនេះ។

គ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ ត្រូវមានយ៉ាងតិចនូវប្រភេទផលិតផលប្រេងសាំងធម្មតា (EA92) និង ប្រភេទផលិតផលប្រេងម៉ាស៊ូតសម្រាប់លក់ជាប្រចាំ ហើយមិនអនុញ្ញាតឱ្យលក់តែប្រេងសាំងស៊ុបពែរតែមួយមុខ ដោយមិន មានលក់ប្រេងម៉ាស៊ូត និងប្រេងសាំងធម្មតា (EA92) បានទេ។

**ប្រការ ៦.-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៤.០០០.០០០ (បួនលានរៀល) ចំពោះស្ថានីយលក់រាយប្រេងឥន្ធនៈទាំង ឡាយណាដែលល្មើសនឹងប្រការ៥ នៃប្រកាសអន្តរក្រសួងនេះ។ ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែល ស្ថានីយលក់រាយប្រេងឥន្ធនៈនោះ អាចនឹងរងនូវការឱ្យបិទផ្អាកប្រតិបត្តិការជាបណ្តោះ អាសន្ន។

**ប្រការ ៧.-**

ការត្រួតពិនិត្យ និងការផាកពិន័យកំណត់ក្នុងប្រការ ៦ ខាងលើ ត្រូវអនុវត្តដោយមន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល របស់ក្រសួងពាណិជ្ជកម្ម ដោយសហការជាមួយមន្ត្រីជំនាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល។

**ប្រការ ៨.-**

រាល់ចំណាយលើការទិញព័ត៌មាន MOPS ដែលលក់ដោយក្រុមហ៊ុននៅប្រទេសសិង្ហបុរី ជាបន្ទុករបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ ៩.-**

ក្រសួងពាណិជ្ជកម្មត្រូវនាំមុខក្រសួងពាក់ព័ន្ធរៀបចំប្រជុំរៀងរាល់ ៦ខែម្តង ឬតាមការចាំបាច់ជាមួយក្រុមហ៊ុនប្រេង ឥន្ធនៈ ដើម្បីពិនិត្យឡើងវិញអំពីតម្លៃ PREMIUM របស់ ស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជា។

**ប្រការ ១០.-**

ប្រកាសអន្តរក្រសួងនេះ មិនគ្របដណ្តប់ទៅលើការងាររបស់សមត្ថកិច្ច ដែលកំពុងអនុវត្តកាតព្វកិច្ចយកពន្ធនោះទេ ។

**ប្រការ ១១.-**

ប្រកាសអន្តរក្រសួង លេខ២៣៨ពណ.អវឯ.ប្រក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការកំណត់រូបមន្តសម្រាប់ កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធដែលស្ថិតក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើតខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨

| ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល |
|---|---|---|
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ប៉ាន សូរស័ក្តិ** | **ស៊ុយ សែម** |

**<u>ចម្លងជូន</u>**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១២*
- *រាជកិច្ច*
- *ឯកសារ -កាលប្បវត្តិ*